# សុន្ទរកថារបស់**ឯកឧត្តម គូម៉ាម៉ារ៉ូ យូជិ**
## ឯកអគ្គរាជទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា
## ថ្លែងក្នុងពិធីចុះហត្ថលេខាលើកិច្ចសន្យាផ្តល់ជំនួយសម្រាប់
## គម្រោងទ្រង់ទ្រាយតូចសន្តិសុខមនុស្សជាតិរបស់ប្រទេសជប៉ុន

២៨ តុលា ២០១៣

**សូមគោរព លោក បប ចេខប នាយករងប្រចាំប្រទេស អង្គការសាម៉ារីតាន់ ភឺស (សង្គ្រោះ អន្តរជាតិ)!**
**សូមគោរព លោក ផែម ម៉ូដែល នាយកវិទ្យាល័យភ្នំធំ ស្រុកមង្គលបុរី ខេត្តបន្ទាយមានជ័យ!**
**សូមគោរព លោក ពៅ តូ ប្រធានការិយាល័យអប់រំ យុវជន និងកីឡាស្រុកកំពង់ត្របែក ខេត្តព្រៃវែង!**
**សូមគោរព អស់លោក លោកស្រី!**

ថ្ងៃនេះ ខ្ញុំមានសេចក្តីសោមនស្សរីករាយដើម្បីចុះហត្ថលេខាលើកិច្ចសន្យាផ្តល់ជំនួយចំនួន៤សម្រាប់គម្រោងទ្រង់ទ្រាយតូចសន្តិសុខមនុស្សជាតិ។ ខ្ញុំក៏មានសេចក្តីសោមនស្សរីករាយយ៉ាងខ្លាំងផងដែរដែលកិច្ចសន្យាផ្តល់ជំនួយទាំងនេះត្រូវបានធ្វើឡើងក្នុង ឆ្នាំ២០១៣ដែលជាឆ្នាំខួបអនុស្សាវរីយ៍ ទី៦០ នៃទំនាក់ទំនងមិត្តភាពជប៉ុន-កម្ពុជា។

គម្រោងទាំង៤ ដែលយើងបានចុះហត្ថលេខានៅថ្ងៃនេះ មានគោលដៅកែលម្អបរិស្ថានអប់រំ សម្រាប់កុមារនៅតំបន់ជនបទ។ ខ្ញុំជឿជាក់ថាការពង្រឹងវិស័យអប់រំគឺជាគន្លឹះសំខាន់សម្រាប់ការអភិវឌ្ឍ និងវិបុលភាពរបស់ប្រទេសកម្ពុជានាពេលអនាគត។ ដូច្នេះខ្ញុំសង្ឃឹមថាជំនួយឧបត្ថម្ភរបស់ជប៉ុននឹងរួមចំណែកទៅក្នុងវត្ថុបំណងនេះ។

ជាការពិតណាស់ ប្រទេសជប៉ុនបាននិងកំពុងបន្តជួយដល់វិស័យអប់រំនៅកម្ពុជាអស់រយៈពេល២ទស្សវត្សមកហើយតាមរយៈការផ្តល់ជំនួយឧបត្ថម្ភសម្រាប់សាងសង់អគារសិក្សា និងកិច្ចសហប្រតិបត្តិការបច្ចេកទេសសម្រាប់ការបណ្តុះបណ្តាលគ្រូបង្រៀន។ គម្រោងទាំងនេះត្រូវបានផ្តល់ជូនតាមរយៈជំនួយគូសាណូណិដែលត្រូវបានបង្កើតឡើងដើម្បីលើកស្ទួយសន្តិសុខមនុស្សជាតិសម្រាប់ប្រជាជនងាយរងគ្រោះ ហើយអនុវត្តតាមរយៈការស្នើសុំរបស់រដ្ឋបាលថ្នាក់ខេត្ត និងអង្គការមិនមែនរដ្ឋាភិបាល។

ជំនួយទី១ មានថវិកាសរុប ៩៧,៤៣១ ដុល្លាអាមេរិកផ្តល់ជូនអង្គការសាម៉ារីតាន់ ភឺស(សង្គ្រោះអន្តរជាតិ) សម្រាប់ការសាងសង់អគារសិក្សា (មួយខ្នងបួនបន្ទប់) និងបំពាក់សម្ភារឹមនៅសាលាបឋមសិក្សាប៉ោយអង្គរ និងសាលាបឋមសិក្សាខ្នាយក្នុងស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ។ យើងសង្ឃឹមថាគម្រោងនេះនឹងកែលម្អបរិស្ថានអប់រំ សម្រាប់សិស្សានុសិស្ស ប្រមាណ ជាង៣៩០នាក់ នៅសាលាបឋមសិក្សាទាំងពីរ។

ជំនួយទី២មានថវិកាសរុប១០៧,០៧៨ដុល្លាអាមេរិកផ្ដល់ជូនអនុវិទ្យាល័យភ្នំជំក្នុងស្រុកមង្គលបុរី ខេត្តបន្ទាយមានជ័យសម្រាប់សាងសង់អគារសិក្សាពីរខ្នង(១០បន្ទប់)និងបរិក្ខារអនាម័យ ព្រមទាំងបំពាក់សង្ហារឹម។ យើងសង្ឃឹមថាគម្រោងនេះនឹងផ្ដល់បរិស្ថានអប់រំប្រកបដោយសុវត្ថិភាព និងផាសុខភាពដល់សិស្សានុសិស្សប្រមាណ៦៨០នាក់ដែលបច្ចុប្បន្នកំពុងប្រើប្រាស់អគារសិក្សាចាស់ទ្រុឌទ្រោម។

ជំនួយទី៣មានថវិកាសរុប១០៣,៨២៤ដុល្លាអាមេរិកផ្ដល់ជូនការិយាល័យអប់រំ យុវជននិងកីឡាស្រុកកំពង់ត្របែក ខេត្តព្រៃវែងសម្រាប់សាងសង់អគារសិក្សាដែលមានកម្ពស់ខ្ពស់មួយខ្នងមាន៤បន្ទប់ និងបរិក្ខារអនាម័យ ព្រមទាំងបំពាក់គ្រឿងសង្ហារឹមដែលចាំបាច់នៅសាលាបឋមសិក្សាអង្គរអង្គ។ យើងរំពឹងថាគម្រោងនេះនឹងជួយកែលម្អបរិស្ថានសិក្សារបស់សិស្សានុសិស្សប្រមាណជាជាង២០០នាក់ដែលបច្ចុប្បន្នកំពុងសិក្សាក្នុងអគារដែលតែងតែជន់លិចដោយទឹកជំនន់។

ជំនួយទី៤មានថវិកាសរុប១០២,៨២៤ដុល្លាអាមេរិកផ្ដល់ជូនការិយាល័យអប់រំ យុវជននិងកីឡាស្រុកកំពង់ត្របែក ខេត្តព្រៃវែងសម្រាប់សាងសង់អគារសិក្សាដែលមានកម្ពស់ខ្ពស់មួយខ្នងមាន៤បន្ទប់ និងបរិក្ខារអនាម័យ ព្រមទាំងបំពាក់គ្រឿងសង្ហារឹមដែលចាំបាច់នៅអនុវិទ្យាល័យតាកែវ។ យើងរំពឹងថាគម្រោងនេះនឹងជួយកែលម្អបរិស្ថានសិក្សារបស់សិស្សានុសិស្សជាង១២០នាក់ដែលបច្ចុប្បន្នកំពុងសិក្សាក្នុងអគារដែលតែងតែជន់លិចដោយទឹកជំនន់។

ខ្ញុំសង្ឃឹមថាគម្រោងដែលចុះហត្ថលេខានៅថ្ងៃនេះនឹងត្រូវបានអនុវត្តយ៉ាងរលូន និង ថែទាំយ៉ាងត្រឹមត្រូវដើម្បីឲ្យប្រជាជនកាន់តែច្រើនអាចទទួលបានអត្ថប្រយោជន៍ពីគម្រោងទាំងនេះ។

ចុងក្រោយនេះ ខ្ញុំក៏សង្ឃឹមផងដែរថាកិច្ចសហប្រតិបត្តិការនេះនឹងជួយពង្រឹងជាបន្តទៅទៀតនូវទំនាក់ទំនងមិត្តភាពរវាងប្រជាជនជប៉ុន និងប្រជាជនកម្ពុជា។

សូមអរគុណចំពោះការយកចិត្តទុកដាក់ស្តាប់!